អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Preliminaire

ឯកសារលេខ D308/3/1/19

*តាមនាមប្រជារាស្ត្រខ្មែរ និងតាមនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពី*
*ការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម*
*ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ*

សំណុំរឿងព្រហ្មទណ្ឌលេខ: ០០៤/១/០៧-០៩-២០០៩-អវតក/កសចស (អបជ ៥០)

ចំពោះមុខ: ចៅក្រម ប្រាក់ គឹមសាន ជាប្រធាន
ចៅក្រម Olivier BEAUVALLET
ចៅក្រម ន័យ ថុល
ចៅក្រម Kang Jin BAIK
ចៅក្រម ហួត វុទ្ធី

កាលបរិច្ឆេទ: ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០១៧

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 14 / 11 / 2017
ម៉ោង (Time/Heure): 11:47
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

**សម្ងាត់**

**ដីកាកំណត់កាលបរិច្ឆេទសវនាការរបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ**

**<u>សហព្រះរាជអាជ្ញា៖</u>**

ជា លាង
Nicholas KOUMJIAN

**<u>សហមេធាវីការពារក្តី អ៊ឹម ចែម ÷</u>**

ប៊ិត ស៊ាងលីម
Wayne JORDASH

**<u>សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ÷</u>**

សំ សុគង់
Emmanuel JACOMY
Lyma NGUYEN

០០៤/១/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ៥០)

ឯកសារលេខ D308/3/1/19

**អង្គបុរេជំនុំជម្រះ**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា **បានទទួល** បណ្តឹងឧទ្ធរណ៍ដាក់ដោយសហព្រះរាជអាជ្ញាអន្តរជាតិនៅថ្ងៃទី ៩ ខែ សីហា ឆ្នាំ ២០១៧[1] ប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ)ចេញដោយសហចៅក្រមស៊ើបអង្កេតនៅថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៧ នៅក្នុងសំណុំរឿង ០០៤/១[2]។

**បានយល់ឃើញ** ថា សារណាបណ្តឹងឧទ្ធរណ៍នៅក្នុងសំណុំរឿង បានចប់សព្វគ្រប់ហើយ។

**បានឃើញ**ថា សារណាអំពីសវនាការរបស់អង្គបុរេជំនុំជម្រះ បានដាក់ជាការឆ្លើយតបទៅនឹងសេចក្តីជូនដំណឹងចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០១៧[3]។ សារណាទាំងនេះបានដាក់ដោយមេធាវីការពារក្តី អ៊ឹម ចែម[4] និងសហព្រះរាជអាជ្ញាអន្តរជាតិ[5] នៅថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៧ ព្រមទាំងសារណាដាក់ដោយមេធាវីការពារក្តី នៅថ្ងៃទី ៦ ខែ វិច្ឆិកា ឆ្នាំ ២០១៧[6]។

---

[1]សំណុំរឿង ០០៤/១/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស ("សំណុំរឿង ០០៤/១") បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) ថ្ងៃទី ៩ ខែ សីហា ឆ្នាំ ២០១៧ ឯកសារ D308/3/1។ *សូមមើលផងដែរ* សំណុំរឿង ០០៤/១ ចម្លើយតបរបស់ អ៊ឹម ចែម ទៅនឹងណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកា ដំណោះស្រាយ(សំអាងហេតុ) ថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១៧ ឯកសារ D308/3/1/11។ សំណុំរឿង ០០៤/១ សារណារបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីអំពីជំហររបស់ អ.វ.ត.ក នៅក្នុងប្រព័ន្ធច្បាប់កម្ពុជា ថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ២០១៧ ឯកសារ D308/3/1/9។ សំណុំរឿង ០០៤/១ ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាទាក់ទងនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ(សំអាងហេតុ) ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៧ ឯកសារ D308/3/1/13។ សំណុំរឿង ០០៤/១ ចម្លើយតបរបស់មេធាវីការពារក្តី ទៅនឹងសារណារបស់ដើមបណ្តឹងរដ្ឋប្បវេណី ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១៧ ឯកសារលេខ D308/3/1/18 ។

[2] សំណុំរឿង ០០៤/១ ដីកាដំណោះស្រាយ (សំអាងហេតុ) ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៧ ឯកសារ D308/3។

[3] សំណុំរឿង ០០៤/១ មន្ត្រីសំណុំរឿង អ៊ីមែលសេចក្តីជូនដំណឹងទៅភាគី៖ "សេចក្តីជូនដំណឹងរបស់អង្គបុរេជំនុំជម្រះផ្ញើជូនភាគីនៅក្នុងសំណុំរឿងលេខ ០០៤/១/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ៥០)" ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០១៧។

[4] សំណុំរឿង ០០៤/១ សេចក្តីស្នើសុំម្តិតសម្រាប់សវនាការផ្ទាល់មាត់នៅក្នុងសំណុំរឿង ០០៤/១ ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៧ ឯកសារ D308/3/1/14។

[5]សំណុំរឿង ០០៤/១ សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាស្តីពីសវនាការអង្គបុរេជំនុំជម្រះ ទាក់ទងនឹងបណ្តឹងឧទ្ធរណ៍លើដីកាដំណោះស្រាយ (សំអាងហេតុ) ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៧ ឯកសារ D308/3/1/15។

[6]សំណុំរឿង ០០៤/១ ចម្លើយតបទៅនឹងការសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាស្តីពីសវនាការអង្គបុរេជំនុំជម្រះទាក់ទងនឹងបណ្តឹងឧទ្ធរណ៍លើដីកាដំណោះស្រាយ(សំអាងហេតុ)( D308/3/1/15) ថ្ងៃទី ៦ ខែ វិច្ឆិកា ឆ្នាំ ២០១៧ ឯកលសារ D308/3/1/16។

01540951



**យោងតាម** វិធាន ៧៧ (៣), ៧៧(៥) និង ៧៧(៦) នៃវិធានផ្ទៃក្នុង។

**អាស្រ័យហេតុនេះ សម្រេចថា** សវនាការនឹងធ្វើឡើងនៅសាលសវនាការនៅថ្ងៃ ចន្ទ ទី ១១ ខែ ធ្នូ ឆ្នាំ ២០១៧ និងថ្ងៃ អង្គារ ទី ១២ ខែ ធ្នូ ឆ្នាំ ២០១៧ ហើយ**ជូនដំណឹង**ភាគីថា កាលវិភាគសវនាការត្រូវអនុវត្ត ដូចខាងក្រោម៖

**ថ្ងៃ ចន្ទ ទី ១១ ខែ ធ្នូ ឆ្នាំ ២០១៧៖**

| | |
|---|---|
| ម៉ោង 0៩:៤៥-១0:00 | សេចក្តីថ្លែងការណ៍បើក (១៥ នាទី) |
| ម៉ោង ១0:00-១១:00 | សារណារបស់មេធាវីតំណាងអតីតអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី-មេធាវី សំ សុគង់ មេធាវី Emmanuel JACOMY និងមេធាវី Lyma NGUYEN (១ ម៉ោង) |
| ម៉ោង ១១:00-១២:00 | សារណារបស់សហព្រះរាជអាជ្ញាជាតិ (១ ម៉ោង) |
| ម៉ោង ១២:00-១៣:៣0 | *សម្រាក (១ម៉ោង កន្លះ)* |
| ម៉ោង ១៣:៣0-១៥:៣0 | សារណាបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (២ ម៉ោង) |

**ថ្ងៃ អង្គារ ទី ១២ ខែ ធ្នូ ឆ្នាំ ២០១៧៖**

| | |
|---|---|
| ម៉ោង ១0:00-១២:00 | ចម្លើយតបរបស់មេធាវីការពារក្តីជាតិ/អន្តរជាតិ (២ ម៉ោង) |
| ម៉ោង ១២:00-១៣:៣0 | *សម្រាក (១ ម៉ោង កន្លះ)* |
| ម៉ោង ១៣:៣0-១៥:៣0 | ចម្លើយតបរបស់មេធាវីការពារក្តីជាតិ/អន្តរជាតិ (២ ម៉ោង) |

**ជូនដំណឹង**ថា ប្រសិនបើជនត្រូវចោទមានវត្តមាន តាមរយៈការជូនដំណឹងពីមេធាវី គាត់នឹងទទួលបានសិទ្ធិធ្វើសេចក្តីថ្លែងការណ៍ផ្ទាល់ខ្លួននៅពេលចុងបញ្ចប់នៃសវនាការ។

**ជូនដំណឹង** ថានឹងមិនអនុញ្ញាតឲ្យឆ្លើយតបឡើយ។

**សម្រេច** ថា សវនាការនេះនឹងធ្វើឡើងដោយសម្ងាត់ បន្ទាប់ពីសេចក្តីថ្លែងការណ៍បើក។

**រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០១៧**

**ប្រធានអង្គបុរេជំនុំជម្រះ**

**ប្រាក់ គឹមសាន**